# បណ្ណព័ត៌មានអំពីរោគទឹកនោមផ្អែម សម្រាប់មាតាបិតានិងអ្នកថែទាំ

**Diabetes Information Sheet for Parents and Carers**

NSW GOVERNMENT | Education Public Schools

លោកអ្នកបានប្រាប់ថា លទ្ធផលនៃរោគវិនិច្ឆ័យបានបង្ហាញថាកូនលោកអ្នកកើតរោគទឹកនោមផ្អែម ប្រភេទ 1 (type 1 diabetes)។ សូមអរគុណលោកអ្នកចំពោះការផ្ដល់ព័ត៌មាននេះ។

នៅក្នុងពេលដែលតួនាទីចម្បងរបស់សាលារៀនគឺដើម្បីផ្ដល់ការសិក្សាអប់រំក្ដី ក៏យើងខ្ញុំចង់ឲ្យកូនលោកអ្នកមានអារម្មណ៍ធូរស្រាលនិងរីករាយនៅឯសាលារៀន និងឲ្យលោកអ្នកមានអារម្មណ៍ទុកចិត្តថា កូនលោកអ្នកកំពុងទទួលការថែទាំយ៉ាងល្អប្រសើរដែរ។ នាយកសាលារៀននឹងធ្វើការជាមួយលោកអ្នកដើម្បីរៀបចំឲ្យមានផែនការថែទាំសុខភាពដោយឡែកមួយសម្រាប់កូនលោកអ្នក។ នៅក្នុងកាលៈទេសៈខ្លះ នាយកសាលារៀនអាចត្រូវការជំនួយបន្ថែមពីអាជ្ញាធរសាលារៀនដែលពាក់ព័ន្ធ ក្នុងការកំណត់នូវវិធីល្អបំផុតដើម្បីបំពេញសេចក្តីត្រូវការរបស់កូនលោកអ្នក។ បើលោកអ្នកកំពុងស្វែងរកការសុំចុះឈ្មោះកូនលោកអ្នក ឬបើកូនលោកអ្នកបានចុះឈ្មោះរួចទៅហើយ សាលារៀនប្រហែលជាយឺតយ៉ាវបន្តិច នៅក្នុងពេលកំពុងគិតគូររកមើលនូវការរៀបចំនានាសម្រាប់កូនលោកអ្នក។

ដើម្បីបំពេញតាមសេចក្តីត្រូវការរបស់កូនលោកអ្នក សាលារៀននឹងចាប់យកវិធានការទាំងឡាយដូចតទៅនេះ៖

## ជំហានទី 1។ ការរៀបចំផែនការថែទាំសុខភាពសម្រាប់សិស្សនីមួយៗ

ផែនការនេះនឹងមានរួមទាំង៖

- ព័ត៌មានពិស្តារនៃស្ថានភាពរោគទឹកនោមផ្អែមរបស់កូនលោកអ្នក
- រូបថតមួយសន្លឹករបស់កូនលោកអ្នក
- សកម្មភាពទាំងឡាយដែលសាលារៀននឹងអនុវត្តដើម្បីជួយកូនលោកអ្នកក្នុងការគ្រប់គ្រងរោគទឹកនោមផ្អែមរបស់ខ្លួនគេនៅសាលារៀន និងដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃកង្វះជាតិស្ករនៅក្នុងឈាម ឬកំណើនជាតិស្ករនៅក្នុងឈាម (កម្រិតគ្លុយកូសទាបឬខ្ពស់)
- ការរៀបចំទាំងឡាយសម្រាប់បុគ្គលិកសាលារៀនក្នុងការជួយកូនលោកអ្នក ឧទាហរណ៍៖ ការជួយសិស្សក្នុងការគ្រប់គ្រងស្ថានភាពសុខភាពរបស់ខ្លួន និងការផ្ដល់លក្ខណៈពិសេសសមរម្យទាំងពួង
- ផែនការឆ្លើយតបនៅពេលមានគ្រាអាសន្ន
- ព័ត៌មានសម្រាប់ទាក់ទងលោកអ្នក នៅពេលមានគ្រាអាសន្ន និងព័ត៌មានសម្រាប់ទាក់ទងជនម្នាក់ទៀត នៅពេលដែលមិនអាចទាក់ទងលោកអ្នកបាន
- ការរៀបចំទុកដាក់រូបថតនិងព័ត៌មានអំពីសេចក្តីត្រូវការរបស់កូនលោកអ្នក នៅក្នុងទីកន្លែងដែលយល់ស្របទាំងឡាយ នៅឯសាលារៀន
- ហត្ថលេខារបស់លោកអ្នកព្រមជាមួយនឹងហត្ថលេខារបស់នាយកសាលារៀន ដើម្បីបង្ហាញថាលោកអ្នកបានអានព័ត៌មានលំអិត ហើយថាសាលារៀនបានពិគ្រោះយោបល់ជាមួយលោកអ្នក និងកូនលោកអ្នក នៅក្នុងការបង្កើតផែនការនេះ។

គ្រូពេទ្យព្យាបាលរបស់កូនលោកអ្នកនឹងត្រូវផ្ដល់ព័ត៌មានអំពីលក្ខណៈនៃស្ថានភាពរោគទឹកនោមផ្អែម ព្រមទាំងការប្រើថ្នាំពេទ្យនិងការព្យាបាលនៅគ្រាអាសន្នដ៏សមស្រប។

**កំណត់សម្គាល់៖** មាតាបិតាគួរពិចារណានូវពេលទាំងឡាយដែលសិស្សមិនស្ថិតនៅក្នុងការថែទាំឬការមើលខុសត្រូវរបស់សាលារៀន ហើយគួរធ្វើផែនការឲ្យសមស្រប។ ឧទាហរណ៍៖ ការធ្វើដំណើរទៅកាន់សាលារៀននិងវិលពីសាលារៀនវិញ ព្រមទាំងក្នុងអំឡុងមុនពេលនិងក្រោយពេលការថែទាំនៅសាលារៀន។

## ជំហានទី 2។ ការរៀបចំឯកសារនិងការផ្តល់ថ្នាំព្យាបាលតាមវេជ្ជបញ្ជា

ការព្យាបាលណាមួយដែលកូនលោកអ្នកត្រូវការ នឹងតម្រូវឲ្យមានសំណូមពរជាលាយលក្ខណ៍អក្សរមួយទៅកាន់នាយកសាលារៀន ដោយមានរួមទាំងការណែនាំនានាសម្រាប់ការប្រើថ្នាំពេទ្យ។ លោកអ្នកនឹងត្រូវផ្តល់ទៅឲ្យសាលារៀននូវថ្នាំពេទ្យនិងប្រដាប់ប្រដារប្រើប្រាស់ទាំងពួង ដែលមានស្លាកសរសេរសមរម្យ (ឧទាហរណ៍ៈ ឧបករណ៍ធ្វើតេស្តកម្រិតគ្លុយគូសក្នុងឈាម និងសឺរ៉ាំងចាក់ថ្នាំអាំងស៊ុយលីន)។

សាលារៀននឹងសុំឲ្យលោកអ្នករៀបចំគ្រឿងឧបករណ៍ព្យាបាលរោគទឹកនោមផ្អែមរបស់កូនលោកអ្នកឲ្យរួចជាស្រេចសម្រាប់ការប្រើប្រាស់នៅថ្ងៃនីមួយៗដែលទៅសាលារៀន។

បើលោកអ្នកចង់ឲ្យកូនលោកអ្នកប្រើថ្នាំដោយខ្លួនឯងនៅសាលារៀន លោកអ្នកនឹងត្រូវធ្វើសំណូមពរជាលាយលក្ខណ៍អក្សរមួយ។ នាយកសាលារៀនទទួលខុសត្រូវក្នុងការសម្រេចថាតើសិស្សណាមួយដែលអាចប្រើថ្នាំដោយខ្លួនឯងដោយសុវត្ថិភាព។ នាយកសាលារៀនអាចសុំស្វែងរកឱវាទពេទ្យអំពីបញ្ហានេះ។

លើសពីនេះទៅទៀត សាលារៀនមានកាតព្វកិច្ចថែទាំក្នុងការចាត់ឲ្យមានជំហានសមហេតុផលទាំងពួងដើម្បីធានាថា ការប្រើថ្នាំដោយខ្លួនឯងត្រូវបានធ្វើឡើងដោយសុវត្ថិភាព។ ការមើលខុសត្រូវបន្ថែមគឺជាការចាំបាច់នៅក្នុងស្ថានការណ៍ដែលសិស្សមានវ័យក្មេងឬគ្មានសមត្ថភាព ហើយពឹងផ្អែកលើជំនួយពីជនពេញវ័យ។

នៅពេលដែលសិស្សអាចប្រើថ្នាំដោយខ្លួនឯងបាន ការចូលរួមរបស់សិស្សនោះនៅក្នុងការបង្កើតទម្រង់ការដែលមានសុវត្ថិភាពសម្រាប់ការប្រើថ្នាំពេទ្យតាមវេជ្ជបញ្ជា នឹងមានប្រយោជន៍នៅក្នុងការទទួលកិច្ចសហការពីសិស្សនោះ។

សូមប្រាប់សាលារៀនផងដែរ បើកូនលោកអ្នកពាក់ខ្សែដៃឬខ្សែកដែលមានឆ្លាក់សរសេរព័ត៌មានសម្រាប់គ្រាអាសន្ន។ Diabetes Australia-NSW សូមស្នើឲ្យសិស្សទាំងឡាយពាក់ខ្សែដៃឬខ្សែកដូចនេះ។

## ជំហានទី 3។ ការប្រាស្រ័យទាក់ទងជាមួយគ្រូពេទ្យព្យាបាលលោកអ្នក

សាលារៀនសុំការអនុញ្ញាតពីលោកអ្នកដើម្បីទាក់ទងវេជ្ជបណ្ឌិតព្យាបាលរបស់លោកអ្នក ឬសមាជិកនៃក្រុមថែទាំរោគទឹកនោមផ្អែមរបស់កូនលោកអ្នក បើចាំបាច់។ លោកអ្នកនឹងទទួល*ក្រដាសផ្តល់ការអនុញ្ញាតឲ្យទាក់ទងវេជ្ជបណ្ឌិតព្យាបាល (Authorisation to Contact Medical Practitioner)* ដើម្បីសរសេរបំពេញ។

## សេវាបកប្រែភាសាតាមទូរស័ព្ទ

បើលោកអ្នកចង់បានព័ត៌មានបន្ថែម សូមទាក់ទងនាយកសាលារៀន។

បើលោកអ្នកត្រូវការជំនួយពីអ្នកបកប្រែភាសា សូមទូរស័ព្ទទៅសេវាបកប្រែភាសាតាមទូរស័ព្ទ ដែលមានលេខ 131 450 ហើយសុំរកអ្នកបកប្រែជាភាសារបស់លោកអ្នក។ អ្នកទទួលទូរស័ព្ទនឹងទូរស័ព្ទទៅសាលារៀន និងរៀបចំឲ្យមានអ្នកបកប្រែភាសាម្នាក់តាមទំនាក់ទំនងទូរស័ព្ទនោះដើម្បីជួយលោកអ្នកក្នុងការពិភាក្សាជាមួយនាយកសាលារៀន។ លោកអ្នកនឹងទទួលសេវានេះដោយឥតគិតថ្លៃ។

សេចក្តីថ្លែងអំណរគុណ។ ឯកសារនេះត្រូវបានចងក្រងឡើងតាមរយៈការទទួលជំនួយពី Diabetes Australia-NSW ។